## CAP អាចជួយអ្នកបាន

- ស្វែងយល់ថាតើអ្នកមានលក្ខណៈសម្បត្តិទទួលបានសេវាការងាររបស់ក្រសួងស្តារលទ្ធភាពពលកម្ម (Department of Rehabilitation (DOR)) ដើម្បីជួយអ្នកស្វែងរកការងារធ្វើដែរឬទេ។
- ស្វែងយល់ពីរបៀបក្នុងការបង្កើតគម្រោងការងារមួយ ដែលអាចរួមបញ្ចូលនូវគម្រោងស្វ័យការងារផងដែរ។
- ដឹងកាន់តែច្រើនបន្ថែមទៀតអំពីសេវាកម្មដែលអ្នកអាចទទួលបានពី DOR និងមជ្ឈមណ្ឌលសម្រាប់ការរស់នៅដោយឯករាជ្យ (Independent Living Centers)។
- ធ្វើការតស៊ូមតិដើម្បីទទួលបានសេវាកម្មដែលសមស្របសម្រាប់អ្នក។




## របៀបទាក់ទងកម្មវិធី Client Assistance Program (CAP) (កម្មវិធីជំនួយអតិថិជន)

អ្នកអាចទាក់ទងទៅកាន់ Client Assistance Program (កម្មវិធីជំនួយអតិថិជន) បានដោយហៅទៅលេខទូរសព្ទឥតគិតថ្លៃ៖
**1-800-776-5746** ឬ
**1-800-719-5798 (TTY)**

---

DRC ជួយដល់ពលរដ្ឋដែលមានពិការភាពឲ្យយល់ដឹងអំពីសិទ្ធិរបស់ពួកគេ ក្លាយជាអ្នកតស៊ូមតិឲ្យខ្លួនឯង និងផ្តល់នូវការតំណាងផ្នែកផ្លូវច្បាប់នៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងពិការភាព។

កម្មវិធីនៃ
**Disability Rights California**
*California's Protection and Advocacy System*

www.disabilityrightsca.org

#5474.06 (Cambodian)



# CAP

# របៀបដែល Client Assistance Program (កម្មវិធីជំនួយអតិថិជន) អាចជួយអ្នកបាន

Disability Rights California

## Client Assistance Program (CAP) (កម្មវិធីជំនួយអតិថិជន)

អង្គការសិទ្ធិជនពិការរដ្ឋកាលីហ្វ័រញ៉ា ផ្តល់ជូនសេវាកម្មរបស់ CAP នៅទូទាំងរដ្ឋ។ CAP ផ្តល់នូវព័ត៌មាន ដំបូន្មាន និងការគាំទ្រដើម្បីជួយដល់ពលរដ្ឋដែលមានពិការភាពឲ្យទទួលបានសេវាការងារពី DOR ដូចជាការបណ្តុះបណ្តាល ការអប់រំ និងការងារជាដើម។ CAP ជួយការពារសិទ្ធិរបស់ពលរដ្ឋដែលទទួលបានឬត្រូវការសេវាកម្មពី DOR, មជ្ឈមណ្ឌលសម្រាប់ការរស់នៅដោយឯករាជ្យ ឬដៃគូផ្សេងទៀតដែលទទួលបានមូលនិធិពីច្បាប់ស្តីពីការស្តារលទ្ធភាពពលកម្ម (Rehabilitation Act)។

## តើអ្នកណាដែលអាចទទួលបានសេវាកម្មរបស់ CAP?

ពលរដ្ឋដែលមានពិការភាពដែលទទួលបានឬត្រូវការសេវាកម្មតាមរយៈ DOR, មជ្ឈមណ្ឌលសម្រាប់ការរស់នៅដោយឯករាជ្យ ឬដៃគូផ្សេងទៀតដែលទទួលបានមូលនិធិពីច្បាប់ស្តីពីការស្តារលទ្ធភាពពលកម្ម។

ដើម្បីសម្រេចចិត្តថាតើយើងអាចធ្វើជាតំណាងឲ្យអ្នកដោយផ្ទាល់ឬអត់ យើងពិនិត្យមើលលើលក្ខណៈនៃករណីរបស់អ្នក សមត្ថភាពរបស់អ្នកក្នុងការតស៊ូមតិសម្រាប់ខ្លួនឯង ប្រភពនៃការតស៊ូមតិផ្សេងទៀតដែលអ្នកអាចប្រើប្រាស់បាន ថាតើបញ្ហារបស់អ្នកជាចំណុចអាទិភាពរបស់ DRC ឬអត់ ឬថាតើ DRC មានធនធាននានាសម្រាប់ជួយឬអត់។

## ទំនួលខុសត្រូវរបស់អ្នក

- ចូលរួមក្នុងកម្មវិធីស្តារលទ្ធភាពការងារជាមួយ DOR។
- រក្សាទុកសំណៅថតចម្លងនៃកំណត់ត្រា DOR របស់អ្នក។
- ប្រាប់អ្នកប្រឹក្សាយោបល់របស់អ្នកអំពីការផ្លាស់ប្តូរដែលប៉ះពាល់ដល់សេវាកម្មឬគោលដៅ DOR របស់អ្នក។
- សាកសួរ ប្រសិនបើអ្នកមិនយល់។



## សិទ្ធិរបស់អ្នក

- ដាក់ពាក្យស្នើសុំសេវាកម្មនិងស្វែងយល់ថាតើអ្នកមានសិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ផ្អែកទៅតាមច្បាប់ដែរឬទេ។
- ចូលរួមក្នុងការវាយតម្លៃបំណិននិងចំណាប់អារម្មណ៍ការងាររបស់អ្នក និងបង្កើតគម្រោងការងារសម្រាប់បុគ្គល (IPE)។
- ទទួលបានសំណៅថតចម្លងមួយច្បាប់នៃគម្រោង IPE របស់អ្នក និងការជូនដំណឹងជាលាយលក្ខណ៍អក្សរមួយច្បាប់ ប្រសិនបើ DOR ចង់ធ្វើការផ្លាសប្តូរ ឬបដិសេធសេវាកម្មរបស់អ្នក ឬបិទសំណុំរឿងរបស់អ្នក។
- ត្រួតពិនិត្យ IPE របស់អ្នកមួយឆ្នាំម្តង។
- ដាក់បណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចរបស់ DOR ប្រសិនបើអ្នកមិនឯកភាពនឹងសេចក្តីសម្រេចនោះ និងរក្សាទុកសេវាកម្មរបស់អ្នកនៅពេលកំពុងដំណើរការបណ្តឹងឧទ្ធរណ៍នោះ។
- ធ្វើការសម្រេចចិត្តដែលមានព័ត៌មានគ្រប់គ្រាន់និងមានខ្លឹមសារ និងមានការប្រព្រឹត្តិចំពោះដោយភាពថ្លៃថ្នូរ។
- ទទួលបានសេវាកម្មដែលសមស្របឲ្យបានឆាប់រហ័សនិងដោយគ្មានការពន្យារពេល។
- អនុវត្តការងារទៅតាមគោលដៅការងារ ដែលផ្តល់ឲ្យអ្នកនូវឱកាសដើម្បីធ្វើការងារនៅកន្លែងដែលអ្នកចូលចិត្តនិងទទួលបានប្រាក់បៀវត្សរ៍ដូចគ្នានឹងបុគ្គលិកដែលគ្មានពិការភាពដែរ។
- ទទួលបានសេវាកម្មមុនពេលមានការងារ (Pre-Employment Transition Services (Pre-ETS)) ដូចជា "សេវាកម្មសម្រាប់សិស្ស/សេវាកម្មសម្រាប់យុវជន" ប្រសិនបើអ្នកជាជនវ័យជំទង់ ឬជនពេញវ័យនៅក្មេងដែលមានពិការភាព ដូចបានកំណត់ដោយច្បាប់របស់សហព័ន្ធនិងច្បាប់របស់រដ្ឋ។